Department of Primary Industries

បណ្ណព័ត៌មាន 5

# រក្សាវាឲ្យបានស្អាតសំរាប់ទីវាលដាំបន្លែ

## ទម្រង់រៀបចំរបស់ចំការ និងចំណុចឆែកឆេរ និងត្រួតពិនិត្យ

Virginia Brunton & Jeremy Badgery-Parker, Ourimbah

ចំការដែលរៀបចំបានល្អ ពុំគ្រាន់តែធ្វើឲ្យបញ្ហាសត្វចង្រៃមានតិចប៉ុណ្ណោះទេ ប៉ុន្តែការចំណាយដើម្បីគ្រប់គ្រងក៏នឹងមានតិចជាងដែរ។ គឺជាការសំខាន់ណាស់ដើម្បីគ្រោងធ្វើទម្រង់រៀបចំរបស់ចំការលោកអ្នក និងសកម្មភាពទាំងអស់ តាមរបៀបដែលធ្វើឲ្យហានិភ័យដោយសារបញ្ហាដែលមានទៅលើចំការ និងរវាងដំណាំលើចំការមានតិចបំផុត។

*“កន្លែងដាំដុះគឺនៅក្នុងតំបន់ “ស្អាត” ដែលដាក់ឲ្យនៅដាច់ពីតំបន់ “ខាងក្រៅ” ចំការដើម្បីបង្ការកុំឲ្យឆ្លងរោគ”*

## បង្កើតឲ្យមានតំបន់ “ខាងក្រៅ ”

តំបន់“ខាងក្រៅ” ជាកន្លែងនៅសល់នៃដីកម្មសិទ្ធលោកអ្នក មានរួមទាំងផ្ទះរបស់លោកអ្នក និងផ្លូវថ្នល់ និងកន្លែងទាំងអស់ដែលនៅក្រៅទីតាំង។ គោលបំណងឲ្យមានតំបន់ “ស្អាត” និង “ខាងក្រៅ” មួយនៅលើចំការរបស់លោក អ្នកគឺដើម្បីឲ្យលោកអ្នកអាចស្ទាក់ចាប់ឲ្យមានប្រសិទ្ធិភាព និងធ្វើឲ្យការគំរាមកំហែងរបស់សត្វចង្រៃមានតិចបំផុត។ ដោយមានតំបន់

## បង្កើតឲ្យមានតំបន់ “ស្អាត”

ចូរបែងចែកចំការរបស់លោកអ្នកជាពីរ(២)តំបន់ - តំបន់ “ស្អាត” និង តំបន់ “ខាងក្រៅ ” ។ តំបន់ “ស្អាត” គឺជាផ្នែកសំខាន់បំផុតនៃចំការ របស់លោកអ្នក និងត្រូវបានដាក់ឲ្យ នៅដាច់ពីគេ ដើម្បីបង្ការកុំឲ្យឆ្លងរោគ ពីតំបន់ “ខាងក្រៅ”។ ការនេះរាប់បញ្ចូលទាំងកន្លែងដាំដំណាំ ផ្ទះបណ្តុះ គ្រាប់ពូជ និងកន្លែងនៅជាប់ជុំវិញ កន្លែងផលិតភោគផលទាំងនេះ។ គឺមានរួមទាំងរោងសំរាប់វេចខ្ចប់ និងផ្លូវថ្នល់ផងដែរ។

គួរដាក់គ្រឿងបរិក្ខារ និងរោងសំរាប់ ទុកដាក់ដែលមានទុកសម្ភារៈប្រគល់មកពីខាងក្រៅ នៅក្នុងតំបន់ខាង ក្រៅ។ បន្ទាប់មកលោកអ្នកអាចគ្រប់គ្រងយានយន្តដែលទៅមក រវាងរោងទាំងនេះ និងតំបន់ស្អាត។




“ស្អាត” លោកអ្នកអាចរក្សាទីកន្លែងផលិតភោគផលរបស់លោកអ្នកឲ្យនៅស្អាត បំបាត់បញ្ហាសត្វចង្រៃ។ ចូរចងចាំថាពាក្យ “សត្វចង្រៃ” អាចរាប់បញ្ចូលទាំងសត្វល្អិតសត្វចៃ ជម្ងឺ សត្វព្រូន រុក្ខជាតិតូចៗឥតប្រយោជន៍ និងសត្វឯទៀតដែរ។ លោកអ្នកក៏អាចត្រួតពិនិត្យចលនាមនុស្ស យានយន្ត និងសម្ភារៈ ដែលចូលទៅក្នុងទីកន្លែងផលិតភោគផលរបស់លោកអ្នកបាន

**March 2012**, http://www.dpi.nsw.gov.au/factsheets for updates
Primefact 1173 first edition

ដែរ។ ការនេះអាចធ្វើបានដោយមានទ្វារចេញចូល ឬចំណុចឆែកឆេរ និងត្រួតពិនិត្យតាមព្រំដែននៃតំបន់ទាំងពីរ។

ចលនាទៅមករបស់ និយោជិក និងភ្ញៀវទៅក្នុង និងជុំវិញចំការគឺជា របៀបយ៉ាងសាមញ្ញដែលនាំឲ្យសត្វល្អិតចង្រៃ និងជម្ងឺអាចឆ្លងរាលដាល បាន។

## ចំណុចឆែកឆេរ និងត្រួតពិនិត្យ

ចំណុចឆែកឆេរ និងត្រួតពិនិត្យអាចជា ឧទាហរណ៍ ល្វែងសំរាប់លាងសំ អាតយានយន្ត ស្ថានីយសំរាប់លាងសំអាតឧបករណ៍ចាប់កាន់លាងដៃ ការដាក់កម្រិតលើយានយន្ត ឬប្រដាប់លាងជើង។ តាមរបៀបនេះ តំបន់ “ស្អាត” ត្រូវបាន*ដាក់ឲ្យនៅដាច់ពីគេ ដើម្បីបង្ការកុំឲ្យឆ្លងរោគ* ពីគ្រប់ទី កន្លែងដទៃទៀត។

ចំណុចឆែកឆេរ និងត្រួតពិនិត្យបានដាក់កម្រិតនៅតាមកន្លែង ដើម្បីការពារ កុំឲ្យមានចលនាទៅមកនៃមនុស្ស និងយានយន្តដែលគេពុំចង់បាន។ ចូរដាក់ ទ្វារចេញចូល និងដាក់កម្រិតដទៃទៀតលើផ្លូវថ្នល់ និងតាមបណ្ដោយព្រំ ដែនរវាងតំបន់ “ស្អាត” និងតំបន់ “ខាងក្រៅ” ដើម្បីការពារចលនា ទៅមកដោយចៃដន្យ ឬដោយចេតនារវាងតំបន់ទាំងពីរ។ ចូរដាក់ជាសញ្ញា នៅកន្លែងសំខាន់ៗ ដើម្បីក្រើនរំលឹកបុគ្គលិក និងភ្ញៀវឲ្យដឹងថាគេបានចូល មកក្នុងតំបន់ “ស្អាត” ហើយ។ ចូរឲ្យតែមនុស្សដែលមានការអនុញ្ញាត ប៉ុណ្ណោះ ទៅមករវាងតំបន់។

ចូរឲ្យភ្ញៀវ អ្នកបើកបរ។ល។ រាយការណ៍មកការិយាល័យ មុននឹងធ្វើដំណើរ ទៅមកក្នុងចំការ។ ចូរពន្យល់ឲ្យដឹងថា នៅកន្លែងណាដែលគេត្រូវប្រគល់ ទំនិញ ហើយត្រួតពិនិត្យការនេះ។ សូមកុំបណ្ដោយឲ្យភ្ញៀវរៀបជួរគ្នាតាមចិត្ត នៅលើចំការឡើយ។

បើអាចធ្វើបាន ចូរដាក់ល្វែងសំរាប់លាងយានយន្ត និងលាងជើងឲ្យនៅ ចន្លោះតំបន់ស្អាត និងតំបន់ខាងក្រៅ។

ចំណុចឆែកឆេរ និងត្រួតពិនិត្យពុំត្រូវការឲ្យទើសទើងការ ធ្វើការងារលើចំការ ដែលមានប្រសិទ្ធិភាពឡើយ។ ចំណុចទាំងនេះអាចជាសញ្ញាដែលណែនាំភ្ញៀវ ឲ្យរាយការណ៍ទៅការិយាល័យជាដំបូង ដែលលោកអ្នកអាចសួរជាសំនួរ និង ណែនាំអំពីចលនាទៅមករបស់គេ។ ការទុកឲ្យភ្ញៀវធ្វើដំណើរត្រាច់ចរគ្មាន កំណត់ក្នុងចំការ គឺជាការគ្មានសុវត្ថិភាព និងមិនយល់ដឹងសោះអំពីការគ្រប់ គ្រងល្អលើសត្វចង្រៃ។

ការទទួលស្គាល់: ពត៌មាននៅក្នុងការបោះពុម្ពផ្សាយនេះ បានរៀបចំចេញពី រក្សាវាឲ្យបានស្អាត – កាត់បន្ថយការចំណាយ និងការខាតបង់ក្នុងការគ្រប់គ្រង សត្វចង្រៃ និងជម្ងឺនៅក្នុងរោងដាំបន្លែ និងកូនរុក្ខជាតិ។ Badgery-Parker, J and T Burfield 2009 ជាមួយនឹងគំនិត និងឱវាទបានមកពី Sandra McDougall និង Alison Anderson។

© រដ្ឋញូវសោវែល តាមរយៈក្រសួងពាណិជ្ជកម្ម និងវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធ ប្រចាំតំបន់ និងកិច្ចបំរើ ឆ្នាំ២០១០។ លោកអ្នកអាចចម្លង ចែកចាយ និងដោះ ស្រាយជាមួយនឹងការបោះពុម្ពផ្សាយតាមរបៀបផ្សេងពីនេះដោយសេរី ដើម្បីគោល បំណងណាមួយ គឺឲ្យតែលោកអ្នកបានបញ្ជាក់ថាក្រសួងពាណិជ្ជកម្ម និងវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធប្រចាំតំបន់ និងកិច្ចបំរើ គឺជាម្ចាស់កម្មសិទ្ធិនៃការបោះពុម្ពផ្សាយ នេះ។

ISSN 1832-6668

ការប្រកាសមិនទទួលខុសត្រូវ: ពត៌មាននៅក្នុងការបោះពុម្ពផ្សាយនេះ គឺសំអាងលើ ចំណេះដឹង និងការយល់ដឹងនៅក្នុងពេលកំពុងសរសេរ (ខែមីនា ឆ្នាំ២០១២)។ ទោះជាយ៉ាងនេះក្ដី ដោយសារការជឿនលឿនផ្នែកចំណេះដឹង អ្នកប្រើប្រាស់ត្រូវបាន រំលឹកអំពីសេចក្ដីត្រូវការដើម្បីឲ្យប្រាកដច្បាស់ថា ពត៌មានដែលគេពឹងផ្អែកទៅលើ មានលក្ខណៈទាន់ពេល និងសំរាប់ឆែកមើលបច្ចុប្បន្នភាពនៃពត៌មានជាមួយភ្នាក់ងារ សមស្របរបស់ក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម ឬអ្នកផ្ដល់ឱវាទឯករាជ្យសំរាប់ អ្នកប្រើប្រាស់។

ចុះផ្សាយដោយក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម ដែលជាផ្នែកមួយរបស់ក្រសួង ពាណិជ្ជកម្ម និងវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធប្រចាំតំបន់ និងកិច្ចបំរើ។

Trim reference INT 12/24528

Horticulture Australia

ការផលិតប័ណ្ណពត៌មាននេះ និងការបកប្រែភាសាបាន ទទួលការផ្គត់ផ្គង់ប្រាក់មួយ ចំណែកពីគំរោងដែលទទួល ប្រាក់ឧបត្ថម្ភរបស់ HAL អង្គការដំណាំវប្បកម្មអូស្ត្រាលី): *ការដោះស្រាយអំពីគុណភាព និងសុវត្ថិភាពនៃផលិតផលជាមួយអ្នកដាំដុះនៃឧស្សាហ កម្មបន្លែដែលនិយាយភាសាក្រៅពីភាសាអង់គ្លេស* ការផ្ដើមគំនិតនៃកម្មវិធីអភិវឌ្ឍន៍ឧស្សា ហកម្មបន្លែ។